ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៨ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៧

[illegible]
ថ្ងៃ ២៥ ខែមិថុនា ឆ្នាំ២០០៧

# សារាចរណែនាំ

## ស្តីពីការបន្ថែមប្រាក់ពី១៥ទៅ២៥ភាគរយជូន ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន

យោងអនុក្រឹត្យលេខ ៤៥ អនក្រ បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបន្ថែមបៀវត្ស ជូនកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ។

យោងសារាចរណែនាំលេខ ០៣ សអយ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការតំឡើងប្រាក់របប ១៥ ភាគរយ ជូនជនពិការ និវត្តជន និង ជនបាត់បង់សមត្ថភាពការងារ ជាអតីតយុទ្ធជន ។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការណែនាំអនុវត្ត ដូចខាងក្រោម :

១-របៀបបន្ថែមប្រាក់ពី ១៥ ទៅ ២៥ ភាគរយ ត្រូវអនុវត្តតាមរូបមន្តដូចតទៅ :

-ក-ចំពោះជនពិការគ្រប់ប្រភេទ និវត្តជន និងជនបាត់បាត់បង់សមត្ថភាពការងារ ជាអតីតកងកម្លាំងប្រដាប់អាវុធម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សឋានន្តរសក្តិ}}{\text{១០០}}$

-ខ-ចំពោះជនពិការ ជាអតីតក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សសុទ្ធសាធ}}{\text{១០០}}$

-គ-ចំពោះជនពិការ ជាអតីតកងសេនាជន ប្រជាជន កងជីវពល ម្នាក់ៗត្រូវបានបន្ថែម ១០ ភាគរយ តាមរូបមន្តអនុវត្ត : $\frac{\text{១០ x បៀវត្សឋានន្តរសក្តិពលទោ}}{\text{១០០}}$

២-ប្រាក់បន្ថែមដូចបានកំណត់ក្នុងចំណុចទី១ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៧ នេះតទៅ និងត្រូវបញ្ចូលក្នុងបញ្ជីរាយនាមជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ទៅក្នុងជួរប្រាក់បន្ថែមភាគរយ ។

៣-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់ខេត្ត ក្រុង ត្រូវបំពេញបែបបទ និងស្នើសុំសេចក្តីសម្រេច ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្ត ។

- នាយកដ្ឋានសោធនអតីតយុទ្ធជន ត្រូវពិនិត្យ និង លើកមតិជូនឯកឧត្តមរដ្ឋមន្ត្រីសម្រេចជាផ្លូវការ ។

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋាន នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានពាក់ព័ន្ធ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រប់ខេត្ត.ក្រុង ត្រូវអនុវត្តសារាចរណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**អ៊ិត សំហេង**

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ខៀវ ចាញ់
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្តក្រុង
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ឯកសារ កាលប្បវត្តិ